# ការសំភាសន៍របស់លោកយាយ នឿន

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ យាយ នឿន

## ការសង្ខេបពីប្រវត្តិរបស់លោកយាយ នឿន

លោកយាយ នឿន អាយុ56ឆ្នាំ នៅឆ្នាំ 2018លោកយាយ នឿន មានភេទស្រីលោកយាយ នឿន មានទីលំនៅបច្ចុប្បន្ននៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ។

កៈ ចឹងជាដំបូងខ្ញុំអរគុណម៉ាក់យាយដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់ម៉ាក់យាយ ហើយការសំភាសន៍នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិច ដែរមានឈ្មោះថា BYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្តាយ នឹងដូចតាចឹងហាសម៉ាក់យាយ ហើយនៅពេលដែរខ្ញុំបានសំភាសន៍ម៉ាក់យាយហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសម៉ាក់យាយ ចឹងតើម៉ាក់យាយយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេម៉ាក់យាយ?

ខៈ យល់ព្រមតាកូន

កៈ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍ម៉ាក់យាយ ខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍គឺនៅថ្ងៃទី3 ខែ2 ឆ្នាំ2018 ហើយការសំភាសន៍មួយនេះត្រូវបានធ្វើឡើងនៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ៕ ខ្ញុំចង់សួរម៉ាក់យាយមួយថា ឈ្មោះម៉ាក់យាយឈ្មោះពេញមានឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ ឈ្មោះ សេង នឿន ជីតាឈ្មោះ សេង

កៈ អ៊ូ!ឈ្មោះ សេងនឿនណាម៉ាក់យាយ?

ខៈ នឹងហើយឈ្មោះ នឹង

កៈ ចុះមានឈ្មោះ ហៅក្រៅទេម៉ាក់យាយ?

ខៈ ឈ្មោះនឿននឹងហើយ

កៈ ចុះកាលពីតូចនឹងធ្លាប់មាននរណាគេហៅឈ្មោះអីផ្សេងទេម៉ាក់យាយ?

ខៈ អត់មានទេ មានតែឈ្មោះមួយនឹងតាមដែរឪពុក នឹងម្ដាយរបស់ខ្ញុំដាក់អោយនឹងក្មួយ នេះឈ្មោះពិតតែម្ដងនឹង

កៈ ចុះម៉ាក់យាយសព្វថ្ងៃនឹងម៉ាក់យាយអាយុប៉ុន្មានដែរម៉ាក់យាយ?

ខៈ កូនអើយឆ្នាំឆ្លូវ ដូចជាប៉ុន្មានទេនេះអាយុ56ឆ្នាំទេមិនដឹង ប៉ុន្មានទេមិនដឹងទេមិនចេះរាប់ផងនឹងហាសកូន

កៈ ម៉ាក់យាយអាយុ56ឆ្នាំ?

ខៈ ប៉ុន្តែឆ្នាំឆ្លូវ អូនឯងចេះរាប់ទេ

កៈ អូ៎!រាប់ចឹងខ្ញុំអត់ចេះផងនឹង ប៉ុន្តែបើឆ្នាំប៉ុន្មានៗខ្ញុំដឹងថាម៉ាក់យាយឆ្នាំប៉ុន្មាន

ខៈ ដឹងតែឆ្នាំឆ្លូវនឹងឯង

កៈ ប៉ុន្តែម៉ាក់យាយកើតនៅឆ្នាំណាម៉ាក់យាយមានចងចាំទេ?

ខៈ អត់អត់រលើងតែម្ដងនឹងហាស

កៈ ប៉ុន្តែខ្ទង់អាយុ56ឆ្នាំ?

ខៈ គេគុណដឹងតា នៅ ឆ្នាំឆ្លូវនឹង

កៈ ខ្ញុំអត់ចេះរាប់ខ្មែរនឹងហាសម៉ាក់យាយ?

ខៈ គេចេះគេដឹងតា

កៈ ប៉ុន្តែខ្ញុំអត់ដឹងទេ?

ខៈ គេដឹងថាឆ្នាំប៉ុន្មានឆ្នាំប៉ុន្មានគេដឹងតានឹង

កៈ ប៉ុន្តែម៉ាក់យាយប្រាប់ថាម៉ាក់យាយអាយុប៉ុន្មានខ្ញុំចេះគុណនឹងហាស បើម៉ាក់និយាយចឹងខ្ញុំអត់ដឹងទេ?

ខៈ ខ្ញុំដឹងតែឆ្នាំឆ្លូវនឹងហាស

កៈ ម៉ាក់យាយដឹងតែឆ្នាំឆ្លូវហោសម៉ាក់យាយ?

ខ៖ នឹងហើយឪពុកម្តាយប្រាប់ដឹងតែចឹង

ក៖ ប៉ុន្តែអាយុហាប៉ុន្មានម៉ាក់យាយមានដឹងទេ?

ខ៖ អោយនរណាគេរាប់ មាននរណាគេចេះណា?

ក៖ អត់អីទេម៉ាក់យាយបើមិនដឹងចឹងហាស?

ខ៖ ដឹងតែឆ្នាំឆ្លូវនឹងហើយ

ក៖ ចុះម៉ាក់យាយកើតនៅណាម៉ាក់យាយមានដឹងទេ?

ខ៖ ខ្ញុំកើតនៅណាទេ កើតនៅភ្នំពេញ រឺមួយក៏នៅស្រែទេ ខ្ញុំភ្លេចអស់ហើយនឹងហាស

ក៖ ប៉ុន្តែនៅភូមិអី ឃុំអីទៅម៉ាក់យាយ?

ខ៖ នៅភូមិសំរោង ស្រុកស្អាង ខេត្តកណ្តាល

ក៖ អូ៎!នៅខេត្តកណ្តាលណាម៉ាក់យាយ?

ខ៖ ចាំ!នឹងហើយនៅខេត្តកណ្តាល

ក៖ ចុះម៉ាក់យាយមានបងប្អូនចំនួនប៉ុន្មាននាក់ដែរនឹងម៉ាក់យាយ?

ខ៖ មានម្នាក់ឯងនឹងហាស

ក៖ ម៉ាក់យាយអត់មានបងប្អូនទេហោសម៉ាក់យាយ?

ខ៖ បងប្អូនស្លាប់បាត់អស់ហើយនឹងហាស

ក៖ ចុះកាលពីនៅរស់មានប៉ុន្មាននាក់ដែរម៉ាក់យាយ?

ខ៖ មាន3នាក់នឹង

ក៖ ទាំងអស់តែម្តងនឹងមាន3នាក់ហោស?

ខ៖ មាន3នាក់ តែបានស្លាប់អស់2នាក់នៅតែខ្ញុំមួយនឹង

ក៖ ចុះម៉ាក់យាយជាកូនទីប៉ុន្មានដែរម៉ាក់យាយ?

ខ៖ ខ្ញុំជាបងគេ

ក៖ ម៉ាក់យាយជាបងគេចុះប្អូនៗវិញ?

ខ៖ ប្អូនស្លាប់បាត់អស់ហើយនឹងហាស

កៈ ចុះគាត់ស្លាប់នៅពេលណាដែរម៉ាក់យាយ?

ខៈ គាត់ស្លាប់នៅពេលដែរបែកអាពតនឹងហាស
ប៉ុន្តែកាលពីអាពតនឹងមិនដឹងទេពីព្រោះតែគេរើសទាហ៊ានហោស
ខ្ញុំគេចទៅនៅឆ្ងាយទៅនៅតាមកន្លែងឆ្ងាយហោស

កៈ ចុះប្អូនៗគាត់មានឈ្មោះអីគេខ្លះដែរទៅម៉ាក់យាយមានចងចាំទេ?

ខៈ ចាំតាឈ្មោះណុន ហើយឈ្មោះអាម៉ៅ ប្រុសហាស

កៈ អូ៎!ចឹងមានតែ3នាក់ទេ?

ខៈ ចា៎!មានស្រី2ប្រុស1នឹង អាប្អូនបន្ទាប់ខ្ញុំនឹង វាលង់ទឹក វាឆ្កួតជ្រូកហាស
វាលង់ទឹកត្រឹមជង្គង់ហាស វាបង្កាច់ហាស

កៈ អូ៎!គាត់លង់រាក់ដែរម៉ាក់យាយ?

ខៈ នឹងហើយចុះវាបង្កាច់ហោស និយាយទៅគ្រួសាររបស់ខ្ញុំកំសត់ហាស
ខ្ញុំកើតមកកំសត់ហាស វាទៅស្ទូងត្រី ដល់ពេលដែរស្ទូចត្រីក៏វាបង្កាច់ចឹងទៅ
ហើយអ្នកដែរគេជិះម៉ូតូស្មានតែវាមុជទឹកហោស មានដឹងថាវាបង្កាច់ណា

កៈ អូ៎!គេដឹងដែរហោសម៉ាក់យាយ?

ខៈ គេដឹងតាគេជិះម៉ូតូក្បែរថ្នល់នឹងហាស

កៈ ចឹងអ្នកជិះម៉ូតូនឹងក៏មិនដឹងទេ?

ខៈ អត់ដឹងទេគេឃើញគ្រាំៗចឹងទៅ ហាយទឹកត្រឹមជង្គង់នឹងវាឆ្កួតជ្រូកនឹងហាស

កៈ គាត់ស្លាប់នឹងទឹកត្រឹមជង្គង់ហោស?

ខៈ នឹងហើយនឹង ហើយគេស្មានតែវាមុជទឹកនឹងហាស
បើគេដឹងថាលង់ចឹងក៏គេចុះមកជួយដែរនឹងហាស

កៈ បាទត្រូវហើយម៉ាក់យាយ?

ខៈ ចុះវាមានដឹងអីវាបើគ្រាំៗចឹងហាស

កៈ ចុះម៉ាក់យាយមានសាច់រឿងអីទេ កាលពីពួកគាត់នៅរស់ហាស
ដូចជានៅប៉ុនថៅហាសម៉ាក់យាយមានលេងអីជាមួយពួកគាត់ដែរទេ?

ខៈ នៅតូចប៉ុណ្ណឹងខ្ញុំមកនៅភ្នំពេញនឹង

កៈ ប៉ុន្តែពួកគាត់នៅណាដែរទៅម៉ាក់យាយ?

ខៈ កាលពីខ្ញុំនៅតូចៗនឹងខ្ញុំមកនៅភ្នំពេញ

កៈ ប៉ុន្តែពួកគាត់មកនៅភ្នំពេញតែម្តងហោស?

ខៈ ចា៎!ទាំងពុក ទាំងម្តាយអីនឹងហាស

កៈ ទាំងបងប្អូនដែរ?

ខៈ ទាំងបងប្អូនអីនឹងហាស

កៈ ប៉ុន្តែម៉ាក់យាយមានបានធ្វើអីគេដែរទៅ?

ខៈ គេជំលាសទៅនៅស្អាងនឹងហាស ប៉ុន្តែនៅស្រុកស្អាងនឹងហាស ភូមិសំពោងនឹងហាស ស្រុករបស់ខ្ញុំហាស

កៈ ចុះម៉ាក់យាយចូលចិត្តធ្វើអីគេជាមួយបងប្អូនរបស់ម៉ាក់យាយដែរ?

ខៈ កាលពីនៅក្មេងៗអាពតអោយខ្ញុំដេរ

កៈ អោយម៉ាក់យាយដេរហោស?

ខៈ អោយខ្ញុំដេរខោអាវ ក្មេងៗ នឹងយុវជនអីនឹងហាស នៅមានស្នាមដែរតា

កៈ បាទនឹងហើយម៉ាក់យាយ?

ខៈ ដេរកាលពីអាពតហាស

កៈ ចុះម្តាយរបស់ម៉ាក់យាយមានឈ្មោះអីគេដែរ?

ខៈ ឈ្មោះយាយ សាទ ឈ្មោះតាការ

កៈ ចុះពួកគាត់មានអាយុប៉ុន្មានដែរម៉ាក់យាយមានដឹងទេ?

ខៈ ម៉ែរបស់ខ្ញុំគាត់ស្លាប់នៅអាយុ63ឆ្នាំ នឹងដឹងតែគាត់ស្លាប់ប៉ុណ្ណឹងឯង

កៈ ប៉ុន្តែម៉ាក់យាយមិនដឹងថាគាត់ស្លាប់ប៉ុន្មានឆ្នាំទេណាម៉ាក់យាយ?

ខៈ អូ៎!ជាង10ឆ្នាំហើយអូនអើយ ដល់ពេលឥឡូវនឹងពេលដែរយើងអត់ទៅវាវង្វេងអស់ហើយនឹងហាសអូន

កៈ អូ៎!ម៉ាក់យាយវង្វេងហោស?

ខៈ ចា៎! ហើយខ្ញុំជំពាក់គេច្រើនដែរនឹងហាស

កៈ អូ!ម៉ាក់យាយជំពាក់គេដែរហោស?

ខៈ នឹងហើយខ្ញុំទៅវាមិនរួចនឹងជំពាក់គេនឹងហាស ជំពាក់គេ3ខែមិនទាន់អោយគេទេ

កៈ អូ!ជំពាក់គេ3ខែហោស?

ខៈ យើងចេះតែដោះគេមួយដងមួយខែៗហាស

កៈ ចុះឪពុករបស់ម៉ាក់យាយឆ្នាំអីគេដែរម៉ាក់មានដឹងទេ?

ខៈ ឪពុករបស់ខ្ញុំនឹងអត់មានដឹងឆ្នាំគាត់ទេ

កៈ ចុះឪពុករបស់ម៉ាក់យាយធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរ?

ខៈ គាត់បង់សំណាញ់

កៈ គាត់បង់សំណាញ់នេសាទត្រីហោស?

ខៈ គាត់បង់ក្បែរមាត់អូរ ក្បែរមាត់ព្រែក

កៈ បាទម៉ាក់យាយ?

ខៈ យើងយកមកប្តូរអង្ករនឹងហាស

កៈ បាទចឹងហោសម៉ាក់?

ខៈ ថាមួយជាត់នឹងក្រតែម្តងនឹងហាស

កៈ ចុះឪពុករបស់ម៉ាក់យាយគាត់ស្លូតរឺមួយក៏កាចហោសម៉ាក់?

ខៈ អូ!កើតមកមួយជាតិនឹងគ្មានណាបានដូចជាឪពុករបស់ខ្ញុំទេ
អត់ដែរចេះជេរកូនមួយម៉ាត់ណា មិនដែរវៃកូននឹងទេ

កៈ គាត់មិនដែរវៃកូនផង?

ខៈ នឹងហើយមិនដែរអោយកូនមានស្លាក់ស្នាមទេអត់មានទេ គាត់ជាអ្នកកាន់សិល្ប៍ហាស

កៈ អូ!គាត់កាន់សិល្ប៍ហោស?

ខៈ នេះឪពុករបស់ខ្ញុំហាស

កៈ ចុះម្តាយវិញ?

ខ៖  ម្តាយនឹងវៀតណាម ប៉ុន្តែវៀតណាមមកនៅភ្នំពេញនឹងហាស
ទៅយករូបថតអត់បានទេ ហើយសំរាប់ឪពុកវិញហាស
គេយកទៅបាត់3ខែបានយកមកវិញ

ក៖  អូ៎!ចឹងហោស?

ខ៖  ខ្លាចបាត់ដូចរបស់ម៉ែហាស ម៉េចគ្រាន់បានរូបថតមើល

ក៖  ចុះម៉ាក់យាយគិតថា……..?

ខ៖  ឪពុករបស់ខ្ញុំលំបាកហាស លុយអាអូនឯងទុកហារបើគាត់ចេះយក
ឪពុករបស់ខ្ញុំគាត់ត្រង់ ឪពុករបស់ខ្ញុំគ្រូទាយថាគាត់ខុសតែបន្តិចទេ
តាមត្រូវគាត់ក្លាយជាព្រះពុទ្ធហាស

ក៖  អូ៎!ឡូយម៉េស?

ខ៖  គាត់កាន់សិល្ប៍ទាល់តែស្លាប់ ហើយគាត់ជិតស្លាប់នឹងក៏នៅថ្វាយបង្គំដៃរនឹងហាស

ក៖  បាទម៉ាក់យាយល្អ?

ខ៖  ឪពុករបស់ខ្ញុំគាត់ស្លូតណាស់ មិនមែនដូចជាខ្ញុំទេ

ក៖  បាទម៉ាក់យាយនឹងហើយ?

ខ៖  អត់រហូតហើយនឹង

ក៖  ចុះម្តាយរបស់ម៉ាក់យាយគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរម៉ាក់យាយ?

ខ៖  ម៉ែរបស់ខ្ញុំគាត់អត់ធ្វើអីផងនឹងគាត់នៅតែផ្ទះ

ក៖  គាត់នៅតែផ្ទះ ចុះគាត់ស្លូតរឺមួយក៏កាចដែរម៉ាក់យាយ?

ខ៖  ហឺគាត់កាចដែរនឹងហាស គាត់មិនវៃទេតែគ្រាន់តែគាត់និយាយច្រើន

ក៖  អូ៎!ចឹងហោសម៉ាក់យាយ?

ខ៖  តែឪពុករបស់ខ្ញុំគាត់ជាអ្នកស្លូអោយហួបទៀតម្តាយរបស់ខ្ញុំគាត់ស្រនុកណាស់
ឪពុករបស់ខ្ញុំគាត់ស្លូដាំ ទោះគាត់មកពីហាត់ក៏ដោយ
ក៏គាត់នៅតែដាក់ដាំបាយស្លូដៃរនឹងហាស

ក៖  អូ៎!ឡូយណាស់?

ខ៖  តែមិនស្រួលនឹងម្តាយរបស់ខ្ញុំនឹងជេរទៀត

ក៖ អូ!ចឹងបាទម៉ាក់យាយ?

ខ៖ វាចឹងទៅវិញហោស

ក៖ ចុះម៉ាក់យាយ
មានចងចាំពីកាលពីម៉ាក់យាយនៅជាមួយម្ដាយឪពុករបស់ម៉ាក់យាយទេថាធ្លាប់ធ្វើអីគេជាមួយគាត់ចឹងហាស?
ខ៖ គាត់នឹងហោស?

ក៖ ធ្លាប់មានអនុស្សាវរីយ៍អីជាមួយគាត់ដែរទេ?

ខ៖ ឪពុករបស់ខ្ញុំគាត់កំសត់ហាស គាត់រកស៊ីចិញ្ចឹមកូនមិនដែរល្អកកករទេនឹងហាស

ក៖ អូ!គាត់ល្អណាស់ម៉ាក់យាយចឹងហោស?
ខ៖ ចាំគាត់សុខចិត្តហូបតែទឹកទេ ត្រីសុខចិត្តទុកអោយកូនស៊ី អោយកូនហូបទៅសាច់គាត់ហូបតែទឹកទេនឹងហាស សូម្បីតែឆ្អឹងក៏ដោយ

ក៖ គាត់ស្រលាញ់កូនខ្លាំងណាស់ចឹងហោស?

ខ៖ ចាំ!មិនដឹងថាជាតិណាបានជួបគាត់ទៀតទេនឹងហាស

ក៖ ចុះយាយតាខាងឪពុកម៉ាក់យាយមានស្គាល់ឈ្មោះគាត់ដែរទេម៉ាក់យាយ?

ខ៖ ស្គាល់តា

ក៖ យាយតាខាងឪពុកគាត់មានឈ្មោះអីគេដែរ?

ខ៖ គាត់ឈ្មោះសេកមិញនឹងខ្ញុំដាក់ត្រកូលតាតានឹងហាស

ក៖ បាទចុះយាយវិញ?

ខ៖ គាត់ឈ្មោះសេក គាត់ចិនគាត់មិនចេះខ្មែរទេនឹងហាស

ក៖ អូ!ចុះយាយវិញ?

ខ៖ យាយឈ្មោះយាយហ៊ីន

ក៖ ចុះយាយតាខាងម្ដាយ?

ខ៖ ស្គាល់តា

ក៖ ពួកគាត់មានឈ្មោះអីគេដែរ?

ខ៖ ឈ្មោះតាប៊ុត នឹងយាយយ៉ា

ក៖ ប៉ុន្តែពួកកាត់កើតនៅឆ្នាំណាៗម៉ាក់យាយអត់ដឹងទេណ?

ខ៖ អត់ដឹងទេ អូនអើយវង្វេងអស់ហើយនឹងហាស

ក៖ បាទម៉ាក់យាយ
ចុះឪពុកម្ដាយរបស់ខ្ញុំម៉ាក់យាយគាត់មានធ្លាប់និយាយពីប្រវត្តិគាត់កាលពីនៅក្មេងប្រាប់យាយទេ?

ខ៖ គាត់ប្រាប់ចឹងដែរ ថាគាត់ ឪពុកខ្ញុំមែន?

ក៖
បាទឪពុកម្ដាយគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីកាត់នៅក្មេងៗអីទេប្រាប់ទៅម៉ាក់យាយហាស?

ខ៖ អត់ប្រាប់ផងនឹងហាស

ក៖ អត់ដែរប្រាប់ទេណម៉ាក់យាយ?

ខ៖ ប៉ុន្តែប្រវត្តិចេះខ្ញុំដឹងថា ម៉ែរបស់ខ្ញុំនឹងគាត់មេម៉ាពោះធំហាស

ក៖ អូ៎!ចឹងគាត់មេម៉ាយ?
ខ៖ នឹងហើយគេយកប្ដីរបស់គាត់ទៅបាត់ទៅនឹងហាស គេមកស្រុកតាកែវហាស
គេមកស្រលាញ់ឪពុករបស់ខ្ញុំនឹងហើយគេយកទៅបាត់ទៅណាស់
គាត់មានប្ដីមុនឈ្មោះតាណុយ

ក៖ អូ៎!គាត់មានប្ដី2ណម៉ាក់?

ខ៖ ចាំ!គាត់មានទំងន់5-6ខែ ហើយឪពុករបស់ខ្ញុំគាត់នៅកំលោះ ហើយគាត់អាណិត
ចុះគាត់មានសិល្បិ៍ក្នុងខ្លួនហាស
គាត់មានធម្មមេត្តាគាត់ទៅឆ្លងទន្លេគាត់ទៅដុតភ្លើងតានឹងហាស
ដល់ពេលដែរគាត់ទៅដុតភ្លើងចឹងទៅគាត់ក៏អាណិតក៏គាត់យកតែម្ដងទៅណាស់

ក៖ គាតើអាណិតយាយ?

ខ៖ ចាំ!កាលពីគាត់ក្មេងស្គរអូនឯងចឹងហាស តែម៉ែខ្ញុំក៏គាត់ក្មេងដែរគាត់កូនដំបូងនឹង
គាត់ក្មេងដូចថាគាត់15-16ឆ្នាំអីចឹងហាស គាត់ក៏អាណិតក៏គាត់យកទៅនឹងហាស
គាត់ក៏ដុតភ្លើងយកទៅណាស់ វាចឹងឯង

កៈ អូ!ចឹងទេណម៉ាក់យាយ?

ខៈ នឹងម៉ែរបស់ខ្ញុំគាត់និយាយប្រាប់ប្រវត្តិរបស់គាត់ហាស
ហើយគេយកប្ដីរបស់គាត់ហើយនៅមុខគាត់ទៀតនឹងហាស

កៈ អូ!ចឹងចុះពុកម៉ាក់យាយគិតយ៉ាងម៉េចដែរ?

ខៈ គេយកនៅមុខគាត់ហើយ ហើយគេនៅស្រុកនឹងទៀត

កៈ ចុះម៉ាក់យាយមករស់នៅទីក្រុងភ្នំពេញនឹងយូរនៅ?

ខៈ ម៉ែនៅស្រែតា ប៉ុន្តែមករកស៊ីនឹងហាស

កៈ អូ!ប៉ុន្តែមកនៅប៉ុន្មានឆ្នាំដែរហើយនឹង?

ខៈ នៅជាងមួយឆ្នាំនឹង

កៈ ទើបតែជាងមួយឆ្នាំទេណា?

ខៈ ចា៎!មួយឆ្នាំនឹងចូលពីរឆ្នាំឆ្នាំនេះហើយនឹង

កៈ ចុះមានកូនចៅណាទៅរស់នៅក្រៅប្រទេសទេ?

ខៈ អត់មានទេកូនអើយមានតែម្នាក់ឯងនឹងក្មួយ កូនសុទ្ធតែក្រនៅក្នុងបឹង
នៅភ្នំស្អាងហោសកូនស្គាល់ដែរទេ?

កៈ បាទស្គាល់តា

ខៈ នឹងទៅរកត្រីក្បែរភ្នំនឹងហោស ហើយហត់ហាស រកត្រីបានគ្រាន់តែសងគេនឹងហាស
អាអូននិយាយចឹងបានហើយចង់បន្ទោសគ្នាក៏ពិបាកដែរពីព្រោះយើងគ្មានដីចែកគ្នាទេ

កៈ អូ!បាទម៉ាក់យាយ?

ខៈ គ្មានរកបាទដៃទទេនឹងឪវានឹងហាស

កៈ អូ!ចឹងហោសម៉ាក់យាយ?

ខៈ បាទដៃទទេសុទ្ធតែម្ដង ហើយទិញដីគេអស់750$
ហើយទិញនឹងអង្គការជឿអោយទៀតនឹង គេបញ្ចាំ1000$
ដល់ពេលហើយលក់អោយកូនរបស់ខ្ញុំតែ750$ទេនឹងហាស
ដល់ពេលដៃរខ្ញុំអង្វរថាអត់លុយទៅក៏យកតែ650$ទេនឹងហាសគេអាណិតខ្ញុំហាសអាស៊ីលី
ដាគេអាណិតហាស ដូចថាគេធ្វើបុណ្យផងគេយក650$នឹងហាស

កៈ  បាទម៉ាក់យាយថោកដែរនឹងហាស?

ខៈ  មាន650$មានអាលក់អោយយើងមាន300$ទៀតនឹងហាស
ដល់ពេលនេះកូនរបស់ខ្ញុំយកប្លង់គេនឹង យកទៅដាក់បង្គ្រប់អោយគេទៅ
ចឹងបានបានដីនៅនឹងហាស

កៈ  ចុះស្វាមីរបស់ម៉ាក់យាយមានឈ្មោះអីគេដែរម៉ាក់?
ខៈ  ឈ្មោះ យាន ប៉ុន្តែបែកគ្នាតាំងពីអាយុម៉ែអាយុម្ភៃជាងនោះ

កៈ  ប៉ុន្តែពេលណុងមានកូននៅម៉ាក់យាយ?

ខៈ  មានកូន6-7នាក់ហើយនឹងហាស ខ្ញុំការតាំងពីអាយុ15ឆ្នាំហោសប្តីរបស់ខ្ញុំនឹងហាស
កាលពីបែកនឹងមានលោក មកពីណា

កៈ  អូ៎!ចឹងហោសម៉ាក់យាយ?

ខៈ  ចា៎!ប៉ុន្តែការ មានតែខ្ញុំទេដែរការមុនដំបូងទេក្នុងភូមិនឹង
បន្ទាប់ពីនឹងមានពីរបីនាក់ទៀតទៅប៉ុន្តែអត់មានលោកទេនឹងហាស

កៈ  ចឹងហោសម៉ាក់យាយ?

ខៈ  ម៉ែការបែកហើយហាស ម៉ែនៅស្គាល់កាត់ដេរអត់ស្គាល់ពន្លឺថ្ងៃទេនឹងហាស

កៈ  ចឹងណាម៉ាក់យាយ?

ខៈ  ចា៎!ប៉ុន្តែប្តីរបស់ខ្ញុំវាខ្មៅទេណាស់ឪរបស់វានឹងហាស ខ្ញុំនឹកឃើញចេះទេនេះ
នឹកឃើញថាសខ្លាចគេធ្វើបាប់នឹងហាស ក៏យកប្តីខ្មៅទៅចឹងហាស

កៈ  អូ៎!ចឹងក៏យកប្តីខ្មៅទៅ?

ខៈ  នឹងហើយពេលដែរហៃកូនកំលោះគេបាញ់កាំភ្លើង
ចុះខ្វះអីគ្រាប់របស់អាពតនឹងហោស

កៈ  បាទម៉ាក់យាយ?

ខៈ  ដល់ពេលដែរលើកកំណត់ពេលព្រឹកហោស គេថាក្អែកពាំពង់មាន់

កៈ  ចុះពេលដែរតាចូលស្តីដណ្តឹងយាយនឹង ដូចជាតាមានជាជំនូនអោយម៉ាក់យាយទេ?

ខៈ  ការចូលស្តីនឹង មិនមែនអីទេកាលណុងចងស្រូវនឹងអូនអើយ

កៈ  អូ៎!គេចងស្រូវហោស?

ខ៖ នឹងហើយការរបស់ខ្ញុំបើគិតពីការឥឡូវនឹង ប្រហែលជាមិនបានប្រហែលការរបស់ខ្ញុំទេនឹងហាស មានគោស្វាវមួយប៉ុណ្ណាណី ហើយមានជ្រូកមួយជាង100គីឡូទៀតនឹងហាស

ក៖ អូ៎!ច្រើនដែរហោសម៉ាក់យាយ?

ខ៖ នឹងហើយយើងហូបតែសាច់ទេ ចុះតុអាពតវាមានវែងៗនោះ

ក៖ បាទម៉ាក់យាយ?

ខ៖ ការក៏កំសត់ដែរនឹង ប៉ុន្តែមានភ្លេងមានភ្លេងបងជីដូនមួយជួយចឹងហាស

ក៖ អូ៎!ឡូយដែរតាម៉ាក់?

ខ៖ នឹងហើយភ្លេងយើងភ្លេងការធម្មតានឹងហាស តែអាអូនមានបីភូមិហាស

ក៖ អូ៎!មានបីភូមិហោស?

ខ៖ ការរបស់ខ្ញុំនឹងវាមានបីភូមិហាស មកនឹងរកកន្លែងអង្គុយគ្មានទេនេះហោស សឹងតែរកកន្លែងអង្គុយមិនបានទេនឹងហាស

ក៖ បាទម៉ាក់យាយ ចុះម៉ាក់យាយមានចេះភាសាខ្មែរបានល្អប៉ុណ្ណាដែរម៉ាក់យាយ?

ខ៖ ខ្ញុំ បើខ្ញុំខ្មែរនឹង

ក៖ ប៉ុន្តែមានចេះអានរឺចេះសរសេរខ្មែរអីទេនឹងហាស?

ខ៖ ចេះតាចេះខ្លះដែរនឹងហាស

ក៖ ប៉ុន្តែរៀនបានថ្នាក់ទីប៉ុន្មានដែរម៉ាក់យាយ?

ខ៖ ថ្នាក់ទីប៉ុន្មានបើយើងយកគ្រូទៅវៃចោលបាត់ហើយនឹង

ក៖ អូ៎!ចឹងហោសម៉ាក់យាយ?

ខ៖ រៀនបានតែ10ថ្ងៃនឹង យើងចេះប្រកបអក្សរខ្លះដែរនឹងហាស

ក៖ ប៉ុន្តែឥឡូវនឹងនៅតែចេះចឹង?

ខ៖ ចេះគួរសម ប៉ុន្តែមិនចេះណាស់ណាទេនឹងហាស

ក៖ បាទល្អហើយចឹងម៉ាក់យាយ?

ខ៖ ពីព្រោះតែឥឡូវនឹងវាងងឹតភ្នែក ប៉ុន្តែអាចមើលដាច់ខ្លះដែរ

កៈ ប៉ុន្តែកាលបីម៉ាក់យាយរៀននឹង តើម៉ាក់យាយរៀននៅណាដែរ?

ខៈ ខ្ញុំរៀននៅក្នុងភូមិនឹងហាស

កៈ រៀននៅភូមិនៅស្អាងនឹងហោស?

ខៈ នឹងហើយ នៅដើមពោធ៍នឹងហាស

កៈ ចុះសាលាឈ្មោះអីគេម៉ាក់យាយមានចងចាំទេ?

ខៈ អត់មានទេ គេហៅថាសាលាដើមពោធ៍នឹងហាស

កៈ អូ្ន!ចឹងហោសបាទ?

ខៈ ដូចថាគេធ្វើនៅដើមពោធ៍ចឹង កាលពីជំនាន់ពលពតនឹងហាស

កៈ បាទម៉ាក់យាយធ្វើនៅដើមពោធ៍?

ខៈ ធ្វើបាយធ្វើអីនឹង មានតុវែងៗហាសណា មិនក្មេងរៀននៅនឹង

កៈ អូ្ន!បាទចុះម៉ាក់យាយមានចេះភាសាអីក្រៅពីភាសាខ្មែរទេ?

ខៈ អត់ទេនឹងកូនអើយ

កៈ ភាសាថៃ វៀតណាមអីអត់ចេះដែរ?

ខៈ ចេះតែមួយនឹងគត់នឹង អត់មានចេះអីទេ

កៈ អូ្ន!ចឹងហោសម៉ាក់យាយ?

ខៈ តែបើមួយម៉ាត់ពីរអានឹងស្តាប់បានខ្លះដែរនឹងហោស គេទិញត្រីទិញចឹងទៅ គេនិយាយភាសាវៀតណាមយើងចេះតែចេះខ្លះដែរចឹងទៅ

កៈ បាទល្អម៉ាក់យាយ?

ខៈ មួយម៉ាត់ពីរម៉ាត់នឹង បើអោយចេះខ្លាំងអត់មានទេ

កៈ ចុះម៉ាក់យាយមានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាទេ?

ខៈ គ្មានទេអូនអើយ

កៈ អត់ដែរមានមិត្តភក្តិទេណាម៉ាក់យាយ?

ខៈ អត់ទេនឹងហាស អ្នកក្រៅគេអាណិតគេអោយបន្លែ អោយអីចឹងទៅ

កៈ អូ៎បាទម៉ាក់យាយ?

ខៈ នេះចៅឃើញដូចកុកចឹងហាស នៅមានបងមួយទៀត

កៈ ចឹងនៅមានបងមួយទៀត?

ខៈ បងនៅរត់លេងរល់ល្ងាច
អោយតែព្រឹកឡើងយើងថាអូនយកតែ2000រៀលបានហើយហី
វានៅឈរសំឡក់យើងចឹងហាស បោះកាតាបចោលចឹងទៅ

កៈ នេះហោសម៉ាក់យាយ?

ខៈ នៅឈរយំចឹងទៅ

កៈ អូចឹងហោសម៉ាក់យាយ?

ខៈ ម៉ែសុខចិត្តជឿម៉ូតូគេទៅ

កៈ អូ៎!យ៉ាប់ដែរនឹង?

ខៈ ហើយស្អែកមិនបាច់ទៅរៀនទេ ពីព្រោះតែអត់លុយទេនឹង

កៈ ស្អែកថ្ងៃអាទិត្យនឹង?

ខៈ មានតែលុយ9000រៀលទេ
មិនមែនអីទេចង់អោយចៅឆាប់ចេះទៅអាងនឹងទៅផ្ទះទៅសំបែងចឹងទៅណាស់
នៅនេះរៀនវាឆាប់ចេះហាស នៅស្រែនឹងវារៀនមិនងាយចេះទេ

កៈ បាទត្រូវហើយម៉ាក់យាយ?

ខៈ វៃក្មេងសុទ្ធតែដាក់ម្រាមដៃចឹងហាស

កៈ អូ៎!ចឹងហោសម៉ាក់យាយ?

ខៈ មិនមែនដូចគ្រូនៅភ្នំពេញទេ គេសុទ្ធតែជួលហាស គេស៊ីប្រាក់ខែ ចឹងហាស
មើលចៅរបស់ខ្ញុំគេចេះអានអីខ្លះដែរហើយនឹងហាស

កៈ អូ៎ឡូយហើយចឹង?

ខៈ វារៀនថ្នាក់ទី1ហាសអាបងហោស

កៈ ចុះម៉ាក់យាយមានធ្លាប់ទៅធ្វើការនៅវាលស្រែទេ?

ខ៖ មានធ្វើអីមានតែស្ទូងស្រូវ ស្ទូងអីនឹងហាស

ក៖ អូ្ន!ម៉ាក់យាយធ្លាប់ធ្វើហោស?

ខ៖ បញ្ហាជាងគេនឹងគឺបញ្ហាអត់លុយពេលដែរកូនឈឺនឹងត្រូវលក់ដីអស់មួយដុំនឹង

ក៖ អូ្ន!ចឹងម៉ាក់យាយ?

ខ៖ កូនឈឺពលថ្នាំពេទ្យមកពេទ្យលោកសង្ឃហោស អស់មួយក្បាលទៀត ឥឡូវនឹងគ្មានដីទេនឹង អោយតែកូនឈឺលក់អស់ហើយនឹងហាស

ក៖ បាទចឹងម៉ាក់យាយម៉េចទៅចឹង?

ខ៖ ចឹងបានរត់មកនៅភ្នំពេញនឹងហាស

ក៖ ចុះម៉ាក់យាយមានធ្លាប់លក់ដូរអីមួយក៏ចិញ្ចឹមសត្វអីទេ?

ខ៖ ម៉ែលក់តា

ក៖ លក្ខណះចិញ្ចឹមមាន់ ចិញ្ចឹមទា?

ខ៖ នឹងហើយមានតា

ក៖ ចុះម៉ាក់យាយគិតថាម៉ាក់យាយមានធ្លាប់ធ្វើអីគេខ្លះនៅក្នុងជិវិតរបស់ម៉ាក់យាយដែរ?

ខ៖ ម៉ាក់យាយនឹងធ្វើតែស្រែទេនឹងហាស ហើយប្ដីរកត្រី

ក៖ អូ្ន!ចឹងហោសម៉ាក់យាយ?

ខ៖ ប៉ុន្តែដល់ពេលដែរលក់ដីអស់ទៅប្ដីរកត្រីតែម្នាក់ឯងនឹងហាស

ក៖
បាទចុះម៉ាក់យាយគិតថាជីវិតរបស់ម៉ាក់យាយាមានការផ្លាស់ប្តូរអីគេខ្លះដែរម៉ាក់យាយ?

ខ៖ អូ្ន!អត់មានការផ្លាស់ប្តូរអីទេ អត់មានការផ្លាស់ប្តូរសោះតែម្ដងគឺអត់មានទេ?

ក៖ អត់ទេចឹងហោសម៉ាក់យាយ?

ខ៖ បើម្ដាយអត់ទេគេឃើញតៅគេ ចែកនេះចែកនោះអោយទៅ សូម្បីតែរនាបមួយអត់ផងនឹងហាស

ក៖ អូ្ន!ចឹងណាស់ម៉ាក់យាយ?

ខ៖ ម៉ែក្រដែរនឹងហាស ហើយឪពុកបង់សំណាញ់អីចឹងហាស

កៈ បាទចឹងហើយម៉ាក់យាយ?

ខៈ សំខ្ញុំអត់មានផងនឹង ចែកដីកូនខ្លះៗដែរចឹងហាស
សល់ដីមួយកូនដុំទុកចែកកូននឹងហាស

កៈ បាទចុះម៉ាក់យាយចូលចិត្តពិសារម្ហូបអីគេខ្លះដែរម៉ាក់យាយ?

ខៈ ម្ហូបធម្មតាខ្ញុំចូលចិត្តតែសម្លម្ហូបសាច់គោអីនឹងហាស

កៈ អូ៎!ស្ងោរ ស្លអីចឹងទៅ?

ខៈ ស្ងោរ ស្លម្ជូរគ្រឿងនឹងហាស ខ្ញុំចូលចិត្តណាស់

កៈ ចុះម៉ាក់យាយចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេដែរតាំងពីក្មេងហាស?

ខៈ អូ៎!អត់ចេះសុទ្ធនឹងហាស

កៈ អត់ចេះផងហោស?

ខៈ ឥឡូវនឹងចេះខ្លះដែរ ឥឡូវនឹងស៊ីគូរថៃពិបាកចិត្តអី200រៀលអីចឹងទៅ

កៈ អូ៎!ចឹងហោស?

ខៈ ហូបបាយក្មួយ បានហើយឈប់ទៅកូន

កៈ អត់អីទេ នេះគ្រាន់តែដំកុលទុកអោយយើងតា?

ខៈ ចឹងហោស

កៈ ចឹងសំរាប់ ខ្ញុំសុំបន្តបន្តិចទៀតចឹងហាស
ចុះម៉ាក់យាយមានបងប្អូនរឺមាននរណាមួយដែរចេះលេងឧបករណ៍ភ្លេងទេ?

ខៈ អត់ទេ បងចេះភ្លេងប្រលងជាប់លេខមួយតែម្តងហាស មកភ្នំពេញឈ្មោះបងហឺហាស

កៈ អូ៎!បាទម៉ាក់យាយឡូយដែរ?

ខៈ ប៉ុន្តែឥឡូវនឹងគាត់ស្លាប់បាត់ហើយនឹង

កៈ អូ!គាត់ស្លាប់បាត់ហើយហោស?

ខៈ ការរបស់ខ្ញុំគាត់មានយកលុយណាមកលេងភ្លេងអោយ ទាំងប្តីទាំងប្រពន្ធនឹង

កៈ បាទម៉ាក់យាយ?

ខៈ ប្រពន្ធរបស់គាត់ពូកែរាំ រាំឡើងទន់តែម្តង ប្រពន្ធនៅទេ តែប្តីស្លាប់បាត់ហើយនឹងហាស

កៈ ចុះម៉ាក់យាយចេះច្រៀងទេ?

ខៈ អត់ចេះទេ

កៈ ប៉ុន្តែម៉ាក់យាយចូលចិត្តស្តាប់បទចំរៀងទេ?

ខៈ ចូលចិត្តដែរប៉ុន្តែកាលនៅពីក្មេងទេណា ប៉ុន្តែឥឡូវនឹងចូលចិត្តធិមវិញ

កៈ ម៉ាក់យាយចូលចិត្តធិមហោសម៉ាក់?

ខៈ ចាំ!ចូលចិត្ត ម៉ែយាយចេះធិមច្រើនដែរ

កៈ អូ៎!ចឹងម៉ាក់យាយសព្វថ្ងៃនឹងរៀនធិមណាម៉ាក់យាយ?

ខៈ អត់រៀនផងនឹង ប៉ុន្តែកាលពីនៅផ្ទះនោះនឹងទិញសៀវភៅនៅតាខ្មៅ
ម៉ាក់យាយចេះតែមើលហើយប្រកបចឹងទៅណា

កៈ អូ៎!ចឹងហោសម៉ាក់យាយ?
ខៈ ប៉ុន្តែឥឡូវនឹងងងឹតហើយនឹងហាស

កៈ បាទម៉ាក់យាយមើលមិនឃើញទេ?

ខៈ នឹងហើយទើបតែយំហើយនឹងហាសកូនក៏ទៅ អត់ដឹងថាម៉ែញាក់
ហើយសន្តិសុខហាសិនយកលុយទេពីព្រោះតែងងឹត ហើយគេបានទិញបបរ
នឹងទិញថ្នាំអោយនឹងហាស

កៈ អូ៎!ចឹងហោសម៉ាក់យាយ?

ខៈ ហើយកូនខ្ញុំវិញគេមិនបានអាណិតខ្ញុំទេ

កៈ ចឹងហោសម៉ាក់យាយ?

ខៈ មើលកូនរបស់ខ្ញុំវាមិនអាណិតទេ ទុកចៅអោយខ្ញុំវាទៅលែងរួចហើយនឹងហាស

កៈ
ផ្ទះរបស់ម៉ាក់យាយមានលក្ខណះបែបណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខៈ ផ្ទះតូចតែរហូតនឹងមិនដែរបានធំនឹងគេទេកូនអើយ

កៈ ផ្ទះឈើហោសម៉ាក់យាយ?

ខៈ ម៉ែគ្មានដីទេ នៅតាមជញ្ជើមថ្នល់នឹងអូន

កៈ  អូ!ចឹងហោសម៉ាក់យាយ?

ខៈ  ដល់ពេលឥឡូវនឹងម៉ាក់យាយមកសុំដីប្អូននៅនឹងហាស

កៈ  បាទចុះកាលពីផ្ទះរបស់ម៉ាក់យាយធ្វើនឹងនរណាគេជាអ្នកធ្វើដែរម៉ាក់យាយ?

ខៈ  កូន កូនៗនឹងហាសនេះម៉ែមីនេះម៉ែនៅជាមួយគេនឹងហាស

កៈ  គាត់ចេះធ្វើផ្ទះហោសម៉ាក់យាយ?

ខៈ  ចាំ!ចេះតា

កៈ  គាត់ធ្វើខ្លួនឯង រឺមួយក៏ជួលគេដែរ?

ខៈ  អង្គការជាអ្នកចែកអោយ

កៈ  អង្គការជាអ្នកចែកអោយហោស?

ខៈ  អង្គការជាអ្នកដែរចែកអោយនឹងហាស ចែកស័ង្កសីខៀវនឹងហាស ជាង60ម៉ឺហាស

កៈ

ចុះម៉ាក់យាយគិតថាម៉ាក់យាយជំនាញអីដែរម៉ាក់យាយគិតថាម៉ាក់យាយចេះជំនាញនឹងជាងគេដែរហាសម៉ាក់យាយ?

ខៈ  ជំនាញបានតែលក់ដូរនឹងម៉ាក់យាយបានធ្វើអីគេកើតដែរ

កៈ  អូលក់ដូរណាម៉ាក់យាយ?

ខៈ  ម៉ាក់យាយក្រពះផងនឹងហាស

កៈ  ចុះឪពុកម្តាយធ្លាប់បង្រៀនពីជំនាញអីទៅម៉ាក់យាយទេ
ដូចជាលក្ខណៈថាជំនាញវេញវល្លិ៍ កូរស្ករត្នោត អីចឹងហាសម៉ាក់យាយ?

ខៈ  ឪពុកម្តាយអត់មានចេះទេ ម៉ែឪពុករបស់ខ្ញុំគាត់អត់ចេះអក្សរផងនឹងហាស

កៈ  អូ!បាទម៉ាក់យាយបាទ?

ខៈ  ចុះមនុស្សចាស់ពីមុននឹងមានចេះអីដែរ

កៈ

ចុះម៉ាក់យាយគិតថាពេលណាដែរម៉ាក់យាយគិតថាពេលណាដែរម៉ាក់យាយពិបាកជាងគេនៅក្នុងជីវិតដែរម៉ាក់យាយ?

ខ៖  ឥឡូវនឹងពុងតែពិបាកមែនទែននឹងហាស

ក៖
ចុះកាលពីជំនាន់ពលពតនឹងកាលពីក្មេងហាសម៉ាក់យាយពិបាកអីគេខ្លះដែរម៉ាក់យាយ?

ខ៖  កាលពីពលពតខ្ញុំបិះស្លាប់បិះរស់នឹង ហូបតែបបរព្រលិតជាមួយត្រីទេនឹងហាស
រស់ដោយសារតែឪពុកបានបង់សំណាញ់ទេបានបង្កងធ្វើអោយរស់នឹងហាស

ក៖  អូ្ហ!ម៉ាក់បានបង្កងទៀត?

ខ៖  មិនមែនគេហៅបង្កងទេប៉ុននេះៗនឹងហាស

ក៖  អូ្ហ!បង្គាហោស?

ខ៖  ដូចបង្គាចឹងប៉ុន្តែគេហៅកូនបង្កងនឹងហាស នៅស្រុកខ្ញុំសំបូរហាស
តែឥឡូវនឹងគេឆកស្លាប់បាត់អស់ហើយនឹងហាស

ក៖  អូ្ហ!ចឹងហោស?

ខ៖  តែឥឡូវនឹងរកតែបង់មួយក៏គ្មានផងនឹងហាស ទៅជាចឹងវិញហាស
ខ្ញុំធំជាងនេះទៅជាចឹងវិញចឹងហាស ដូចតូចជាងផងនៅឆ្នាំ75ហាស

ក៖  បាទម៉ាក់យាយ

ខ៖  នឹងហើយឪពុកជាអ្នកបង់សំណាញ់ខ្ញុំជាអ្នកចាប់ បង់មួយថ្ងៃពីរ
មួយថ្ងៃបីហើយខ្ញុំមកដុតតែអាបង្កង់នឹងហាស ហើយអត់មានអំបិលទេអូន
នៅឆ្នាំ75នឹងគ្មានអំបិលទេ

ក៖  អូ្ហ!ចឹងអត់មានអំបិលទេ?

ខ៖  ឪពុកគាត់យកដេះមកធ្វើជាអំបិលហាសអូន

ក៖  អូ្ហ!យកដេះធ្វើជាអំបិល?

ខ៖  នឹងហើយយកដេះនៅចង្ក្រាននឹងអោយធ្វើជាអំបិលនឹងហាស
យករំងាស់ទឹកបីយកទឹកមួយប្រែលមៗនឹងហាស

ក៖  អូ្ហ!ពិបាកម៉ាក់យាយ?

ខ៖  នឹងហើយយកមករំងាស់វេទនាណាស់ យកមកជ្រលក់អត់ប្រៃផង
យកមកជ្រលក់បង្កងនឹងហាស

កៈ បាទម៉ាក់យាយចឹងហោស?

ខៈ ហើយឪពុកដកព្រលិតហោស
គាត់លាង7យប់7ថ្ងៃនឹងហាសគាត់ក្អួតអត់ចេញទេណាស់
គាត់អត់បាយទេណាស់គាត់ក្អួតអត់ចេញទេណាស់ឪពុករបស់ខ្ញុំគាត់កំសត់ហាសណាស់
ក្អួតអត់ចេញទេនៅឆ្នាំ1975នឹងហាស

កៈ អូ!វេទនា?

ខៈ ចុះគាត់អត់បានហូបបាយចឹងគាត់ក្អួតមានចេញអី មាត់សឹងតែលានហើយនឹងហាស

កៈ ប៉ុន្តែម៉ាក់យាយគេអោយធ្វើអីគេទៅពេលណុងហាស?

ខៈ ខ្ញុំនៅតូចៗនឹងហាស

កៈ គេមិនអោយធ្វើអីទេណា?

ខៈ អត់ទេខ្ញុំនៅតែជាមួយឪពុកម្តាយនឹងហាស

កៈ
បាទៗៗចុះម៉ាក់យាយគិតថាមានអីដែរទាក់ទងនឹងពលពតដែរធ្វើអោយម៉ាក់យាយចងចាំបានទេម៉ាក់យាយ?

ខៈ ពលពតមានតែប្រវត្តិអត់បាយនឹងហាស

កៈ ចឹងហោសម៉ាក់យាយ?

ខៈ នឹងស្ទើរស្លាប់នឹងស្ទើររស់នឹងហាស ហើយឥឡូវនឹងវាដូចជាអាពតចឹងហាស

កៈ អូ!ម៉េចចឹងម៉ាក់យាយ?

ខៈ ដឹងតែអត់បាយស៊ីទៀតនឹងហាស បើប្តីបែកតាំងពីខ្ញុំអាយុម្ភៃជាងនឹងហាស
តាំងពីអាយុ27-28ឆ្នាំខ្ញុំបានលែងហាស

កៈ បាទម៉ាក់យាយលែងគាត់ហោស?

ខៈ ចាំ!ខ្ញុំលែងមករហូតនឹងហាស ហើយខ្ញុំចិញ្ចឹមកូនៗតាំងពីតូចៗមកម្ល៉េស

កៈ បាទម៉ាក់យាយ?

ខៈ ហើយបានអីមានបើខ្ញុំចិញ្ចឹមតូចៗនៅប៉ុណ្ណឹងហាស ម៉ែឪវានឹងនៅតូចហាស
ខ្ញុំដាក់ចោលអត់មានលុយមើលណា ចេះរស់ដែរកើតកញ្រ្ជិល វាលាប់ហាស

កៈ អូ៎!បាទអត់អីទេ?

ខៈ អត់អីដែរចេញតែត្រឹមនឹងហាស ចឹងដាក់ចោលតែម្តង ហើយគេដាក់ស្មៅនេះស្មៅនោះ គេថាត្រូវនឹងហាសគ្រប់កន្លែង ហាត់នឿយនឹងចិញ្ចឹមកូនតែម្តងនឹងហាស

កៈ បាទម៉ាក់យាយមានអីទៀតទេ?

ខៈ ហើយកូនមានអី ត ចែកគ្នាតនឹងហាស

កៈ ចុះបន្ទាប់មកទៀតម៉ាក់យាយមានពិបាកអីទៀតទេ?

ខៈ ឥឡូវនឹងមែន?

កៈ បាទម៉ាក់យាយ

ខៈ ឥឡូវនឹងម៉ែពិបាកត្រង់ថាផ្ទះក៏ជួលគេ

កៈ អូ៎!ជួលផ្ទះគេដែរធ្វើអោយម៉ាក់យាយពិបាក?

ខៈ ពីមុនម៉ែមកលក់ផ្អកដាច់តែឥឡូវនឹង ចូលឆ្នាំមកជួលផ្ទះនៅនឹង ហើយលក់ផ្អកប្រហុកលែងដាច់ហើយនឹងហាស

កៈ អូ៎!ចឹងហោសម៉ាក់យាយ?

ខៈ ថ្ងៃនេះម៉ែលក់មានដាច់ណាសូម្បីតែមួយរយ ដាច់បានយកលាសគេកន្លះតៅនឹងហាសបាន1ម៉ឺននឹងហាស

កៈ អូ៎!បាទចឹងយ៉ាប់?

ខៈ ហើយកន្លែងគេយក5000រៀលទៀតនឹងហាស

កៈ អូ៎!ចុះម៉ាក់យាយដូចជាឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរម៉ាក់យាយ?

ខៈ របៀបថាយើងឈឺខ្ញុំឈឺបីខែនេះមិនបានទៅលក់ផងនឹងហាស

កៈ អូ៎!ឈឺហោសម៉ាក់យាយ?

ខៈ រួចបានអីមាន បើឈឺបើមិនចាក់ នឹងបន្តោងសារ៉ុមម៉េចកើត អត់បានរស់ដល់សព្វថ្ងៃទេណាស់ វាចឹងហាសអូន ចុងដៃ ចុងជើងនឹងបេះដូងហាស

កៈ បាទម៉ាក់យាយ

ខ៖  មានបេះដូងទៀតហាស មានបីបូនមុខហោស បើគេមានវិញហាស
គេទៅមើលខ្លួនគេហើយនឹងហាស តែខ្ញុំវាអត់ចឹងទៅមានតែទ្រាំទៅចឹងហាស

ក៖  បាទម៉ាក់យាយបាទ?

ខ៖  ឥឡូវនឹងផឹកថ្នាំនៅជាយដែននេះហាស ប្រើថៅទៅទិញទេណាស់

ក៖
ចុះពេលណាដែរម៉ាក់យាយគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់ម៉ាក់យាយដែរហោស?

ខ៖  ក្នុងឆាកជីវិតនឹងអត់ដែរមានពេលដែរសប្បាយទេនេះ ក្នុងភ្នែកនឹងងងឹត
នឹងហើមអស់ហើយនឹងហាសយំរហូតនឹងហាស

ក៖  អូ៎!បាទម៉ាក់យាយ?

ខ៖  យកប្ដីនឹងហាស ខំអីមិនលែងទេ ប្ដីផឹកបីកូនមកវិញវៃយើងក៏មានដែរនឹងហាស
វៃអាអូនមានស្នាក់ស្នាមមកដល់ឥឡូវនឹងហាស

ក៖ អូ៎!បាទម៉ាក់យាយ យ៉ាប់ដែរចឹង?

ខ៖  អូ៎!វៃសុទ្ធតែច្រវ៉ាក់ហាស នេះបែកក្បាលហោស ចោលការទឹកនឹង
ធម្មតាការទឹកវាមានពោយចឹងហោស
វាដែកហាសវាគប់អាពោយចឹងទៅចំអាដែកនឹងចំក្បាលយើង
ហើយឈាមហូរពេញមុខអស់នឹងហាស

ក៖  អូ៎!គាត់កាច់ហោសម៉ាក់យាយ?

ខ៖  នឹងហើយបានដាច់លែងពីប្ដីមួយនឹងហាស នៅបាវិតស្វាយរៀងនឹងហាស
ខ្ញុំមិនដែលថា ជាត់ណាក៏ដោយកុំអោយខ្ញុំកើតឆ្នាំឆ្លូវនឹងហាស

ក៖  បាទយ៉ាប់ណាស់?

ខ៖  វេទនាណាស់អូនមែនខ្ញុំបន់ព្រះអង្គរាល់តែថ្ងៃនឹងហាស
ថាអោយខ្ញុំរៀងពីឆ្នាំឆ្លូវនឹងទៅណាស់ ស្រាប់តែគេប្រើដូចគោចឹងទៅ

ក៖  បាទម៉ាក់យាយ?

ខ៖  គេប្រើដូចគោចឹងហាស

ក៖  ចុះម៉ាក់នៅពីតូចម៉ាក់យាយធ្លាប់មានក្ដីស្រម៉ៃថាចង់ក្លាយជាអីទេ?

ខ៖ ស្រម៉ែដែរនឹងហាស ប៉ុន្តែស្រម៉ែថាអោយមានហូបអោយបានត្រឹមត្រូវ អោយរៀនអោយបានចេះនឹងគេចឹងហាស មិនបានធ្វើអីអោយមានជីវភាពធំដុំក៏ដោយអោយតែម៉ែឪសប្បាយនឹងហាស អោយតែហូបចុកហូបបៀរទៅបានហើយមិនចាំបាច់មានបានអីទេនឹងហាស

ក៖ បាទម៉ាក់យាយ?

ខ៖ ត្រឹមតែហូបគ្រប់គ្រាន់ទៅបានហើយនឹងហាស តែក្ដីស្រម៉ៃរបស់ម៉ាក់យាយអត់បានសំរេចទេនឹងហាស

ក៖ ចុះបើចង់អោយម៉ាក់យាយផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗតើម៉ាក់យាយចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរម៉ាក់យាយ?

ខ៖ ផ្ដែផ្ដាំនេះប្រដៅរាល់ថ្ងៃនឹងហាស ប្រាប់ថាចៅឯងមកពីនេះវិញរៀនហាស កុំអោយក្រដូចម៉ាក់យាយចៅឯងខំហាស ឪពុកស្អប់ដូចអាចម៍ចឹងហាស ហើយឪពុកពាក់ស្បែកជើងឡើងសដូចអូនឯងចឹងហាសដូចគ្នា ពាក់ស្បែកជើងបាត់តានោះដឹងតែដើរលេងទេនេះ

ក៖ អូ!ចឹងហោសម៉ាក់យាយ?

ខ៖ តេទៅបើបាន10ម៉ឺនមកទិញទឹកដោះគោទៅ ខ្ញុំស្អប់ដូចជាអាចម៍ចឹងហាស ខ្ញុំជេរដូចថាបាតសង្គមនឹងហាស វាអាងខ្ញុំចិញ្ចឹមចៅនឹងហាសវាដើរតែលេងទេនឹងហាស

ក៖ អូ!យ៉ាប់ដែរ?

ខ៖ វាមានរកស៊ីអីទេនឹងហាស វាផឹករៀចៗផ្សិតហោស ពាងក្រឡអីនឹងខ្ទិចអស់ហើយនឹងហាស

ក៖ ចុះម៉ាក់យាយមានអីចង់ផ្ដែផ្ដាំទៀតទេនឹងហាស?

ខ៖ ខ្ញុំចង់ផ្ដាំថាចេះអាអូនអើយ ប៉ុន្តែនិយាយទៅថាយើងនឹងវាពេកនឹង

ក៖ រឿងអីគេទៅម៉ាក់យាយ?

ខ៖ ដូចថាប៉ុស្ដិ៍ហង្សមាសចឹងហាសណាស់ ខ្ញុំចង់និយាយថា ខ្ញុំចង់សុំជំនួយជាថ្លៃផ្ទះអីបានទេអូនបានចៅរៀនតទៀតនឹងខ្ញុំអាណិតចៅណាស់

ក៖ ខ្ញុំមិនទាន់ដឹងដែរនឹងម៉ាក់យាយ

ខ៖ ខ្ញុំចង់ទឹកភ្នែកមែនតា

ក៖ បាទចឹងហោសម៉ាក់យាយ?

ខ៖ ខ្ញុំចិញ្ចឹមចៅលែងទៅរួចហើយចង់អោយវាទៅស្រុកវិញហើយនឹងហាស

ក៖ បាទម៉ាក់យាយចឹងមានអីទៀតទេ?

ខ៖ មែនហាសអូនសូម្បីតែម្ហូបអីនឹងគេអោយដែរនឹង ខំអីអត់ទៀតនឹងហាស

ក៖ ចុងក្រោយខ្ញុំអរគុណច្រើនម៉ាក់យាយ

ខ៖ ខ្ញុំខ្មាស់អូនឯងហាសនឹង

ក៖

បាទម៉ាក់យាយចឹងខុងក្រោយម៉ាក់យាយដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់ម៉ាក់យាយ ចឹងហាសម៉ាក់យាយ

ខ៖ ខ្ញុំចង់អោយតែអូនឯងជួយម៉ាក់យាយតែប៉ុណ្ណឹងទេ

ក៖ បាទអរគុណច្រើនម៉ាក់យាយ៕៕៕